**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

## សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ករណីព្យាបាលជាសះស្បើយ ជាជនជាតិខ្មែរ ០១នាក់ និងជាជនជាតិម៉ាឡេស៊ី ០១នាក់ នៅខេត្តកែប និង មិនមានករណីវិជ្ជមានកូវីដ១៩ ថ្មី នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

**១. សរុបស្ថានភាពជំងឺកូវីដ១៩ នៅទូទាំងប្រទេស៖** ត្រឹមម៉ោង០៧:០០ព្រឹក ថ្ងៃទី០១ ខែមេសា ឆ្នាំ ២០២០ ស្ថានភាពជំងឺកូវីដ១៩ មានដូចតទៅ៖

– អ្នកព្យាបាលជាសះស្បើយ សរុបចំនួន ២៥នាក់ (ស្មើនឹង ២៣,៣៦ % ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ១៩ទាំងអស់) ដែលមានបុរសជនជាតិចិន ០១នាក់ ស្ត្រីជនជាតិអង់គ្លេស ០២នាក់ បុរសជនជាតិអង់គ្លេស ០១នាក់ បុរសជនជាតិបារាំង ០១នាក់ បុរសជនជាតិម៉ាឡេស៊ី ០១នាក់ និងបុរសជនជាតិខ្មែរ ១៩នាក់ (គិតចាប់ពីខែមករាដល់បច្ចុប្បន្ននេះ)

– អ្នកដែលកំពុងសម្រាកព្យាបាល សរុបចំនួន ៨៤នាក់ (ស្ត្រី ២៨នាក់ និងបុរស ៥៦នាក់) នៅតាមមន្ទីរពេទ្យរដ្ឋនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត

– អ្នកមានវីរុសកូវីដ១៩ ដែលបានរកឃើញទាំងអស់ (រាប់ទាំងអ្នកដែលបានព្យាបាលជាសះស្បើយ និងអ្នកដែលកំពុងព្យាបាល) នៅទូទាំងប្រទេសសរុបចំនួន ១០៩នាក់ (ស្ត្រី ៣០នាក់ និងបុរស ៧៩នាក់)។

**២. ករណីជាសះស្បើយ៖ មាន ០២នាក់ នៅខេត្តកែប**

បុរសជនជាតិខ្មែរអាយុ ៣០ឆ្នាំ (កាន់សាសនាឥស្លាម និងមានទីលំនៅនៅខេត្តកំពត) ដែលបានវិលត្រឡប់មកពីចូលរួមពិធីសាសនានៅប្រទេសម៉ាឡេស៊ី និងបុរសជនជាតិម៉ាឡេស៊ីអាយុ ៦១ឆ្នាំ មកពីប្រទេសម៉ាឡេស៊ី បានជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានវីរុសកូវីដ១៩ចំនួន ០២ លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យខេត្តកែប។

**៣. មិនមានករណី វិជ្ជមានវីរុសកូវីដ១៩ ថ្មី** នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ នោះទេ

**៤. ចំនួនដែលបានធ្វើវិភាគរកវីរុសកូវីដ១៩** គិតចាប់តាំងពីខែមករា មកដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០២០ សំណាកដែលបានធ្វើវិភាគសរុបទូទាំងប្រទេស មានចំនួន ៥.៧៦៤ ករណី។



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨១ ៤០៥ / ៨៨៤ ៩០៩

ក្រុមការងាររបស់ក្រសួងសុខាភិបាល កំពុងតែធ្វើកិច្ចការស្រាវជ្រាវករណីថ្មីជាបន្តទៀត ហើយនឹងបន្តជម្រាបជូនដល់បងប្អូនសាធារណជន ប្រសិនបើមានរកឃើញករណីវិជ្ជមានវីរុសកូវីដ១៩ ថ្មីណាផ្សេងទៀត។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៨២៤ ឬ ០១២ ៨៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃពុធ ០៩កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០១ ខែមេសា ឆ្នាំ២០២០



ទីស្តីការក្រសួងសុខាភិបាល ពីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃ ៣១ ខែមីនា ឆ្នាំ២០២០

### ករណីវិជ្ជមានកូវីដ ១៩ បែងចែកតាមភេទ ក្នុងចំណោម ១០៩ ករណី




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០២០

និន្នាការនៃចំនួនវិជ្ជមានកូវីដ ១៩ សរុបទូទាំងប្រទេសតាមថ្ងៃជូនព័ត៌មាន




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០២០

## ចំនួនករណី វិជ្ជមានកូវីដ ១៩ ដែលបានរកឃើញនៅតាមរាជធានីខេត្ត

## សរុប ១០៩ ករណី




*សំគាល់៖ អ្នកជំងឺពីខេត្តព្រះសីហនុ ០១នាក់ មកព្យាបាលនៅមន្ទីរពេទ្យ មិត្តភាពខ្មែរ-សូវៀត និងអ្នកជំងឺខេត្ត [illegible] ១នាក់ មកព្យាបាលនៅមណ្ឌលសុខភាពតាក់ម៉ៅក្រោម រាជធានីភ្នំពេញ ហើយអ្នកទាំង២បានជាសះស្បើយ*

ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០២០




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០២០

### ចំនួនករណីវិជ្ជមានកូវីដ ១៩ ដែលបានរកឃើញនៅតាមរាជធានីខេត្ត

### សរុប ១០៩ ករណី




*សំគាល់៖ អ្នកជំងឺពីខេត្តព្រះសីហនុ ០១នាក់ មកព្យាបាលនៅមន្ទីរពេទ្យ មិត្តភាពខ្មែរ-សូវៀត និងមកពីខេត្ត ត្បូងឃ្មុំ ១នាក់ មកព្យាបាលនៅមណ្ឌលសុខភាពចាក់អង្រែក្រោម រាជធានីភ្នំពេញ ហើយអ្នកទាំង២បានជាសះស្បើយ។*

ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ៣១ ខែមីនា ឆ្នាំ២០២០

ចំនួនករណីវិជ្ជមានកូវីដ ១៩ ថ្មីដែលបានរកឃើញប្រចាំថ្ងៃ




ប្រភព៖ ក្រសួងសុខាភិបាល